ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស

# សេចក្តីជូនដំណឹង

## ស្តីពី

## ការលើកកាលបរិច្ឆេទប្រលងតេស្តសមត្ថភាពភាសាកូរ៉េលើកទី១៥(15th EPS-TOPIK)តាមប្រព័ន្ធកុំព្យូទ័រ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៨ ទៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨

គណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បេក្ខជន បេក្ខនារី ដែលមានឈ្មោះប្រលងតេស្តសមត្ថភាពភាសាកូរ៉េលើកទី១៥ (15th EPS-TOPIK) តាមប្រព័ន្ធកុំព្យូទ័រ នាថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៨ ទាំង៦៤០នាក់ ឱ្យបានជ្រាបថា ការប្រលងតេស្តសមត្ថភាពភាសាកូរ៉េនេះ ត្រូវបានលើកពេលទៅប្រលងទៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ ដោយរក្សាបន្ទប់ប្រលង និងវេនប្រលងនៅដដែល។

អាស្រ័យន័យដូចបានជម្រាបជូនដំណឹងខាងលើ សូមបេក្ខជន បេក្ខនារី ដែលមានឈ្មោះប្រលងនៅ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៨ ទាំង៦៤០នាក់ មេត្តាជ្រាបជាព័ត៌មាន និងត្រៀមទៅចូលរួមប្រលង នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ វិញ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស ដែលមានទីតាំងអគារលេខ៨ ក្នុងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (NPIC) ភូមិព្រៃពពេល សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឬតាមរយៈទូរសព្ទលេខ ០២៣-៦៥២៥-៧៧៧ / ០២៣-៦៤២៥-៧៧៧ និង ០១២-៤៦៦-២២២ នៅរៀងរាល់ម៉ោងធ្វើការ។

ថ្ងៃសុក្រ ៨កើត ខែទុតិយាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨